# ខោនធី SANTA CLARA

## គម្រោងផែនការរដ្ឋបាលដើម្បីការបោះឆ្នោត

## សេចក្តីបន្ថែម

# តារាងមាតិកា

សេចក្តីផ្តើម ........ 3
ទីតាំងមណ្ឌលបោះឆ្នោត ........ 3
ជំនួយផ្នែកភាសាដែលបានធ្វើបច្ចុប្បន្នភាព ........ 3
វិធីសាស្រ្តក្នុងការផ្សព្វផ្សាយ ........ 4
ការបោះឆ្នោតតាមសំបុត្រដែលអាចធ្វើដំណើរការទៅបានពីចម្ងាយ ........ 5

# សេចក្តីផ្តើម

ដើម្បីចូលរួមជាមួយការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីនាពេលខាងមុខ នៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត (Registrar of Voters, ROV) បានបង្កើតនូវសេចក្តីបន្ថែមទៅលើគម្រោងផែនការរដ្ឋបាលដើម្បីការបោះឆ្នោតបច្ចុប្បន្ន ដើម្បីបំពេញជាពិសេសទៅតាមសេចក្តីទាមទារនៃមណ្ឌលបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាព ដោយបន្ថែមទៅលើភាសាដែលជាសេវាផ្តល់ជូនដោយខោនធី ព្រមទាំងវិធីសាស្ត្រផ្សព្វផ្សាយដែលបានធ្វើបច្ចុប្បន្នភាព ។

# ទីតាំងមណ្ឌលបោះឆ្នោត

នៅថ្ងៃទី 3 ខែមិថុនា ឆ្នាំ 2020 លោកអភិបាល Newsom បានចេញនូវសេចក្តីបង្គាប់ N-67-20 ។ នៅក្នុងសេចក្តីបង្គាប់នោះ លោកបានដកចេញនូវការទាមទារឱ្យខោនធីត្រូវមានមណ្ឌលបោះឆ្នោតបើកទ្វាររយៈពេលដប់ (10) ថ្ងៃ មុនថ្ងៃបោះឆ្នោត ហើយរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតទៀត គឺសរុបដប់មួយ (11) ថ្ងៃ ។ គិតមកទល់នឹងពេលនៃការសរសេរសេចក្តីបន្ថែមនេះ ជំនួសឱ្យការលប់ចេញទាំងស្រុងនៃមណ្ឌលបោះឆ្នោត 11-ថ្ងៃ ដូចដែលច្បាប់អនុញ្ញាត, ROV នឹងផ្តល់ជូនមណ្ឌលបោះឆ្នោតរយៈពេល 11-ថ្ងៃ ចំនួន ប្រាំបី (8) និង មណ្ឌលបោះឆ្នោតប្រើរយៈពេល 4-ថ្ងៃ ចំនួនកៅសិបពីរ (92) ឱ្យបើកអំឡុងពេលនៃការបោះឆ្នោតដំបូង 4-ថ្ងៃ ដែលតម្រូវឱ្យមណ្ឌលបោះឆ្នោតបើក បី (3) ថ្ងៃមុនថ្ងៃ បោះឆ្នោត ហើយរាប់ទាំងថ្ងៃបោះឆ្នោតទៀត សរុបគឺ (4) ថ្ងៃ ។ ការទាមទារសម្រាប់ចំនួននៃមណ្ឌលបោះឆ្នោតប្រើរយៈពេល 4-ថ្ងៃ គឺមណ្ឌលបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតនៅខោនធីដែលបានចុះឈ្មោះរៀងរាល់ 10,000 នាក់ ។ ដោយផ្អែកទៅតាមចំនួនដែលបានគណនានៃចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 នៃការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីនេះ ROV នឹងចាំបាច់ត្រូវមានយ៉ាងហោចណាស់មណ្ឌលបោះឆ្នោតចំនួនមួយរយ (100) ដែលត្រូវបើក ។

ស្ថិតិវិភាគដែលបានធ្វើបច្ចុប្បន្នភាពនៃមណ្ឌលបោះឆ្នោតមានដូចតទៅ ៖

| ចំនួនមណ្ឌលបោះឆ្នោតដែលត្រូវបានធ្វើការប៉ាន់ស្មាន | | | |
|---|---|---|---|
| ខ្សែបន្ទាត់បែងចែក | លក្ខខណ្ឌតម្រូវជាអប្បបរមា | ចំនួនដែលបានស្នើឡើង | ចំនួនដែលត្រូវបានសម្រេចចុងក្រោយ |
| មណ្ឌលបោះឆ្នោតដំណើរការរយៈពេល 4 ថ្ងៃ (1 សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរៀងរាល់ 10k) | 100 | 100 | TBD |

ការគណនានេះគឺផ្អែកទៅលើការមានមណ្ឌលបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតក្នុងខោនធីដែលបានចុះឈ្មោះរួចរៀងរាល់ 10,000 នាក់ ។ ដោយផ្អែកទៅតាមចំនួនដែលបានគណនានៃចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 នៃការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីនេះ ROV នឹងចាំបាច់ត្រូវតែមានបើកយ៉ាងហោចណាស់ចំនួនមួយរយ (100) មណ្ឌលបោះឆ្នោត ។

# ជំនួយផ្នែកភាសាដែលបានធ្វើក្នុងបច្ចុប្បន្នភាព

នៅខែ ឧសភា ឆ្នាំ 2020 ការិយាល័យរដ្ឋលេខាធិការបានបន្ថែមនូវភាសាដែលបានកំណត់អោយមានដោយរដ្ឋនៅក្រោមច្បាប់បោះឆ្នោត (EC) 4201 ស្តីពីការកំណត់ភាសាប្រជាជនភាគតិច ។ ភាសាប្រាំក្នុងចំណោមនោះបានត្រូវបន្ថែមទៅក្នុងភាសាដែលត្រូវបានទាមទារដោយ ខោនធី Santa Clara ៖ ហ្មុយ៉ារាទី នេប៉ាល់ បញ្ចាពី តាមិល និងតេលូហ្គូ ។

ROV នឹងផ្តល់ជូននូវសេវាភាសាទាំងនេះទៅតាមភាសាដែលបានកំណត់ដោយរដ្ឋថ្មីនេះ ៖

| ភាសាដែលបានអោយមានកំណត់ដោយរដ្ឋថ្មី | សេវាកម្ម និង សម្ភារៈបកប្រែ | សន្លឹកឆ្នោតថតចម្លង |
|---|---|---|
| ▪ ហ្គុយ៉ារាទី<br>▪ នេប៉ាល់<br>▪ បញ្ជាពី<br>▪ តាមិល<br>▪ តេលូហ្គូ | • សន្លឹកឆ្នោតថតចម្លងផលិតសម្រាប់ ក្នុងការបោះឆ្នោតទៅតាមមណ្ឌលបោះឆ្នោតគ្រប់តំបន់ទាំងអស់គោលដៅ ក្នុងមួយ EC 14201<br>• បែបបទសុំសន្លឹកឆ្នោតថតចម្លងមានក្នុងគ្រប់ភាសាដែលបានបោះពុម្ពក្នុង CVIGs<br>• បែបបទសុំនៃសន្លឹកឆ្នោតថតចម្លងមាននៅលើគេហទំព័រខោនធីទៅតាម EC 14201<br>• ការណែនាំ និងផ្លាកសញ្ញានៅមណ្ឌលបោះឆ្នោត<br>• បែបបទសុំ VBM<br>• ទម្រង់ស្នើសុំសកម្មភាពរបស់អ្នកបោះឆ្នោត (VARF)<br>• បុគ្គលិកផ្នែកពីរភាសានៅ ROV និងមណ្ឌលបោះឆ្នោត | ការបកប្រែសម្រាប់សន្លឹកឆ្នោតថតចម្លងទាំងស្រុង ៖<br>• ចំណងជើង<br>• សេចក្តីណែនាំ<br>• ឈ្មោះយុត្តាធិការ<br>• ការសរសេរភាសាតាមសូរស័ព្ទដោយផ្អែកលើតួអក្សរ<br>• ការកំណត់ជាមុននៃសន្លឹកឆ្នោត<br>• ស្លាកវិធានការ |

សន្លឹកឆ្នោតថតចម្លងគឺជាសន្លឹកឆ្នោតគំរូដែលអ្នកបោះឆ្នោតអាចប្រើប្រាស់ជាសេចក្តីយោងនៅពេលធ្វើការបោះឆ្នោត ។ ខោនធី of Santa Clara, ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោតនឹងរៀបចំសន្លឹកឆ្នោតថតចម្លងជាភាសាទាំងប្រាំដែលបានបន្ថែមនៅមណ្ឌលបោះឆ្នោតគោលដៅ ។ ច្បាប់ថតចម្លងនៃសន្លឹកឆ្នោតចម្លងនឹងមានសម្រាប់អ្នកបោះឆ្នោតនៅមណ្ឌលដែលបានកំណត់ដើម្បីប្រើប្រាស់នៅពេលធ្វើការទម្លាក់សន្លឹកឆ្នោតឯកជន ។ សន្លឹកឆ្នោតថតចម្លងត្រូវមានរូបរាងខុសគ្នាពីសន្លឹកឆ្នោតធម្មតាដើម្បីការពារមិនឱ្យអ្នកបោះឆ្នោតប៉ុនប៉ងធ្វើការបោះឆ្នោតលើច្បាប់ថតចម្លងនៃសន្លឹកចម្លង ។ បុគ្គលិកធ្វើការនៅមណ្ឌលបោះឆ្នោតនឹងត្រូវបានបណ្តុះបណ្តាលក្នុងគោលបំណងធ្វើការផ្តល់ដំណឹងដល់អ្នកបោះឆ្នោតអំពីវត្តមាននៃច្បាប់ថតចម្លងនៃសន្លឹកឆ្នោតចម្លង និងពីរបៀបក្នុងការផ្តល់នូវសន្លឹកឆ្នោតចម្លង នៅពេលត្រូវបានស្នើដោយអ្នកបោះឆ្នោត ។ សញ្ញាជា 14 ភាសាដែលត្រូវបានផ្តល់ជូនដោយខោនធី (អង់គ្លេស ចិន អេស្ប៉ាញ តាហ្គាឡុក វៀតណាម ខ្មែរ កូរ៉េ ហិណ្ឌី ជប៉ុន ហ្គុយ៉ារាទី នេប៉ាល់ បញ្ជាពី តាមិល និងតេលូហ្គូ) នឹងត្រូវបានបិទបង្ហាញនៅក្បែរសៀវភៅស្រង់ស្ថិតិអេឡិចត្រូនិកនៅក្នុងមណ្ឌលបោះឆ្នោតគោលដៅសម្រាប់ផ្តល់ដំណឹងដល់អ្នកបោះឆ្នោតក្នុងការបោះឆ្នោតទៅតាមមណ្ឌលបោះឆ្នោតគ្រប់តំបន់ទាំងអស់ពីវត្តមាននៃច្បាប់ចម្លងនៃសន្លឹកឆ្នោតថតចម្លង ។

សេចក្តីណែនាំព័ត៌មានអំពីអ្នកបោះឆ្នោតខោនធីទាំងអស់នឹងភ្ជាប់មកជាមួយបែបបទនូវសុំសន្លឹកឆ្នោតចម្លង និងសេចក្តីជូនដំណឹងទាំង 14 ភាសាដោយផ្តល់ដំណឹងដល់អ្នកបោះឆ្នោតថាសន្លឹកឆ្នោតចម្លងមានសម្រាប់អ្នកបោះឆ្នោតនៅមណ្ឌលបោះឆ្នោត និងទៅតាមសំណើទៅតាមច្បាប់បោះឆ្នោត 14201 ។ តារាងកំណត់អត្តសញ្ញាណមណ្ឌលបោះឆ្នោតដែលមានច្បាប់ចម្លងនៃសន្លឹកឆ្នោតដែលមានសម្រាប់អ្នកបោះឆ្នោតនឹងត្រូវបានចុះផ្សាយនៅលើគេហទំព័ររបស់ខោនធីយ៉ាងហោចណាស់ 14 ថ្ងៃ មុនការបោះឆ្នោត ។

# វិធីសាស្រ្តក្នុងការផ្សព្វផ្សាយ

នៅក្រោមក្រុមប្រឹក្សាសុវត្ថិភាព និង សុខភាពដែលបានណែនាំដោយរដ្ឋ និងខោនធី វិធីសាស្រ្តក្នុងការផ្សព្វផ្សាយដោយជួបមុខគ្នាទាំងអស់នៃការជំនួបផ្ទាល់ នឹងត្រូវបានជំនួសដោយវិធីសាស្រ្តផ្សេងទៀតសម្រាប់ការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីនៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ។ វិធីសាស្រ្តនៃការផ្សព្វផ្សាយផ្សេងទាំងនេះរួមមាន ការជួប និងសិក្ខាសាលាបែបនិម្មិត ការបង្ហោះព័ត៌មានជាក្រាហ្វិក និងព័ត៌មានក្នុងការអប់រំតាមបណ្តាញសង្គម ការចែកចាយអត្ថបទបោះពុម្ព និងការបិទផ្សាយនៅទីតាំងសហាគមន៍ដែលមានការពេញនិយមដែលត្រូវបានកំណត់ ។

ការអប់រំដល់អ្នកបោះឆ្នោត និង ក្រុមអ្នកផ្សព្វផ្សាយនឹងធ្វើកិច្ចប្រជុំគណៈកម្មការផ្សព្វផ្សាយ និង ការអប់រំដល់អ្នកបោះឆ្នោតប្រចាំខែនិម្មិត ជាមួយនិងសហាគមន៍ដែលជាដៃគូដើម្បីពិភាក្សាអំពីវិធីសាស្រ្តក្នុងការផ្សព្វផ្សាយក្តីបារម្ភ និងមតិត្រឡប់ទាំងឡាយ ។ យើងក៏នឹងមានវត្តមាននៅក្នុងគ្រប់ការប្រជុំគណៈកម្មការប្រឹក្សាយោបល់ក្នុងការទទួលបានការបោះឆ្នោត និង គណៈកម្មការប្រឹក្សាការជំនួយផ្នែកភាសានិម្មិតផងដែរ ដើម្បីផ្លាស់ប្តូរព័ត៌មានថ្មីៗ ។ ជាមួយនឹងការដាក់បញ្ចូលភាសាប្រាំថ្មីបន្ថែមទៀតនេះ (ហ្មុយ៉ារាទី នេប៉ាល់ បញ្ជាពី តាមិល និងតេលូហ្គូ) ROV និងក្រុមអ្នកផ្សព្វផ្សាយឥឡូវអាចបម្រើជូន 14 ភាសា។ ROV មានគម្រោងធ្វើការដោះស្រាយការទាមទារផ្នែកភាសានីមួយៗតាមរយៈការផ្តល់នូវឯកសារឌីជីថល និង បោះពុម្ពដែលបានបកប្រែរួចជាស្រេច។

បន្ថែមពីនេះទៀត ROV កំពុងធ្វើការជាមួយរដ្ឋ និង មន្ត្រីថ្នាក់តំបន់ដើម្បីធានាឱ្យបានថាមណ្ឌលបោះឆ្នោតដោយផ្ទាល់នឹងមានសុវត្ថិភាព និង អាចប្រើប្រាស់បានសម្រាប់អ្នកបោះឆ្នោតទាំងឡាយដែលត្រូវការ ។ ROV នឹងបង្កើតការផ្ញើសារដើម្បីផ្តល់ដំណឹងដល់អ្នកបោះឆ្នោតពីទីកន្លែងដែលការបោះឆ្នោតដោយផ្ទាល់អាចធ្វើទៅបាន និងអ្វីជាការបំរុងប្រយ័ត្នជាមុនលើសុវត្ថិភាពដែលត្រូវអនុវត្តដើម្បីអាចការពារពួកគេបាន រាប់ទាំងគំលាតសុវត្ថិភាព និង ឧបករណ៍ការពារខ្លួន ។ យើងនឹងចែករំលែកសារនេះជាមួយនឹងបញ្ជីរាយនាមដៃគូរបស់យើង ក្រុមអ្នកប្រឹក្សាយោបល់ដល់ពលរដ្ឋ និងភ្នាក់ងារខោនធីដែលពាក់ព័ន្ធផ្សេងទៀតសម្រាប់ជំនួយរបស់ពួកគេក្នុងការផ្សព្វផ្សាយបន្ថែមនៃព័ត៌មានទៅដល់មនុស្សក្រុមតូចៗទាំងអស់នៅក្នុងខោនធី ។

# ការបោះឆ្នោតតាមសំបុត្រដែលអាចធ្វើដំណើរការទៅបានពីចម្ងាយ

សម្រាប់ការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីថ្ងៃទីនៅ 3 ខែវិច្ឆិកា ឆ្នាំ 2020 ច្បាប់នៃរដ្ឋ California បានអនុញ្ញាតឱ្យអ្នកដែលបានចុះឈ្មោះទាំងអស់ប្រើប្រាស់ប្រព័ន្ធបោះឆ្នោតតាមសំបុត្រដែលអាចធ្វើដំណើរការទៅបានពីចម្ងាយ (RAVBM) ដើម្បីទទួលបាន ទាញយក បោះឆ្នោត និងព្រីនចេញនូវសន្លឹកបោះឆ្នោតរបស់ពួកគេ ។ គោលបំណងនៃប្រព័ន្ធ RAVBM គឺមិនមែនដើម្បីបោះឆ្នោតតាមអ៊ីនធើណិតទេ ។ អ្នកបោះឆ្នោតតាម RAVBM នឹងត្រូវបានទទួលអ៊ីម៉ែលដោយមានតំណភ្ជាប់មកជាមួយ ដើម្បីចូលទៅកាន់សន្លឹកឆ្នោតផ្លូវការរបស់ខ្លួន ព្រមទាំងសេចក្តីណែនាំនានាអំពីរបៀបទាញយកសន្លឹកឆ្នោត ការព្រីនចេញ ការបំពេញ និងការផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោតរបស់ពួកគេមកកាន់ ROV ឲ្យបានត្រឹមនៅថ្ងៃបោះឆ្នោត ។ អ្នកបោះឆ្នោតដោយប្រើប្រាស់តំណភ្ជាប់ដែលបានផ្ញើតាមរយៈអ៊ីម៉ែល ត្រូវតែទាញយកសន្លឹកឆ្នោតទៅក្នុងឧបករណ៍របស់ខ្លួនដើម្បីអាន និង គូសលើសន្លឹកឆ្នោតជាមួយបច្ចេកវិទ្យាជំនួយផ្ទាល់របស់ខ្លួន ។ ដូចគ្នាទៅនឹងអ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយដែរ មានមធ្យោបាយបីយ៉ាងដែលអ្នកបោះឆ្នោត RAVBM អាចផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោតរបស់គេបានគឺ ៖ តាមសំបុត្រធម្មតា ដោយការទម្លាក់សន្លឹកឆ្នោតរបស់គេនៅតាមប្រអប់ទម្លាក់សន្លឹកឆ្នោត ឬ ដោយការបញ្ជូនត្រឡប់មកកាន់មណ្ឌលបោះឆ្នោតណាមួយក៏បាន ។